# មេរោគ West Nile : អ្វីដែលអ្នកត្រូវដឹង

## តើមេរោគ West Nile Virus ជាអ្វី?

មេរោគ វិុសណាលវីរុស (West Nile Virus - WNV) គឺជាជំងឺដ៏ធ្ងន់ធ្ងរមួយអាចបណ្តាលឲ្យស្លាប់ ។ អ្នកជំនាញជាច្រើនជឿជាក់ថា WNV ជាជំងឺរាលដាលតាមរដូវ មាននៅអាមេរិកខាងជើង ដែលច្រើនតែកើតនៅក្នុងរដូវក្តៅ ហើយមានបន្តដល់រដូវស្លឹកឈើជ្រុះ ។ ក្រដាសព្រឹត្តិការណ៍នេះ គឺមានពត៌មាន ដែលអាចជួយអ្នកឲ្យដឹង និងអាចការពារ West Nile Virus (មេរោគវិុសណាលវីរុស) បាន ។

## តើខ្ញុំត្រូវធ្វើអ្វីខ្លះ ដើម្បីការពារ WNV?

វិធីដ៏ស្រួល និងល្អបំផុត ដើម្បីជៀសវៀង WNV គឺការពារកុំឲ្យមូសខាំ ។

- នៅពេលអ្នកចេញទៅក្រៅផ្ទះ សូមប្រើថ្នាំការពារសត្វល្អិតខាំ ដែលមានសារធាតុ DEET (សារធាតុគ្មានពណ៌ ធ្វើឲ្យសត្វល្អិតមិនហ៊ានមកជិត ហើយមានជាតិពុលតិចៗ ) ។ សូមធ្វើតាមសេចក្តីណែនាំពីវិធីការពារនៅលើកញ្ចប់ ។
- មូសភាគច្រើនខាំនៅពេលភ្លឺព្រឹមៗ និងពេលថ្ងៃរះ ។ ធ្វើយ៉ាងណាត្រូវប្រើថ្នាំកំចាត់សត្វល្អិត និងពាក់អាវដៃវែង និងស្លៀកខោជើងវែងនៅពេលភ្លឺព្រឹមៗ និងពេលថ្ងៃរះ ឬពិចារណាអំពីការនៅក្នុងផ្ទះក្នុងកំឡុងពេលនេះ ។ សំលៀកបំពាក់មានពណ៌ភ្លឺៗ អាចធ្វើឲ្យអ្នកមើលឃើញមូសមកទុំនៅលើអ្នក ។
- ធ្វើយ៉ាងណាត្រូវដាក់សំណាញ់បង្អួច និងទ្វារឲ្យបានល្អ ដើម្បីកុំឲ្យមូសចូលមកក្នុងផ្ទះបាន ។
- ត្រូវកំចាត់កន្លែងមូសពង ដោយកុំឲ្យមានទឹកដក់នៅក្នុងថូផ្កា ប៉ោត និងធុង ។ ប្តូរទឹកដាក់ឲ្យសត្វផឹក និងប្តូរទឹកសំរាប់សត្វស្លាបលេងរៀងរាល់អាទិត្យ ។ ចោះរន្ធក្នុងកង់ឡានព្យួរឲ្យក្មេងៗយោលទោង ដើម្បីឲ្យទឹកហូរចេញ ។ ទឹកសំរាប់ដាក់ឲ្យកូនក្មេងលេងមិនត្រូវឲ្យមាននៅសល់នៅពេលដែលក្មេងមិនងូតទឹក សោះឡើយ ។

## តើ WNV មានរោគសញ្ញាអ្វីខ្លះ?

WNV ធ្វើឲ្យប៉ះពាល់មណ្ឌលប្រពន្ធ័សរសៃប្រសាទ ។ រោគសញ្ញាគឺមានលក្ខណៈផ្សេងៗពីគ្នា ។

- **រោគសញ្ញាមានលក្ខណៈធ្ងន់ធ្ងរ ក្នុងចំណោមមនុស្សមួយចំនួន ។** ប្រហែលជាមានម្នាក់ក្នុងចំណោមមនុស្ស 150 នាក់ ដែលមានមេរោគ WNV នឹងឈឺដ៏ធ្ងន់ធ្ងរ ។ រោគសញ្ញាដ៏ធ្ងន់ធ្ងរនោះរួមមានដូចជា គ្រុនក្តៅខ្លាំង, ឈឺក្បាល, រឹងក, ធីងធោង, វង្វេងវង្វាន់, សន្លប់, ញ័រដៃជើង, ប្រកាច់, ខ្សោយសាច់ដុំ, មើលមិនឃើញ, ស្ពឹក និងកំរើកលែងរួច ។ រោគសញ្ញាទាំងនេះអាចមានជាច្រើនអាទិត្យ ហើយការប៉ះពាល់ដល់ប្រពន្ធ័សរសៃប្រាសាទអាចមានជាអចិន្ត្រៃយ៍ ។

- **រោគសញ្ញាដែលមានលក្ខណៈស្រាលជាង ក្នុងចំណោមមនុស្សខ្លះ ។** រហូតដល់ទៅ 20 ភាគរយនៃមនុស្សដែលមានមេរោគ WNV នឹងក្លាយជាមានរោគសញ្ញាដូចជា គ្រុនក្តៅ, ឈឺក្បាល, ឈឺខ្លួន, រមួលពោះ, ក្អួត ហើយជួនកាលហើមក្រពេញទឹករងៃ ឬកន្ទួលស្បែកដើមទ្រូង, ដំបារពោះនិងខ្នង ។ រោគសញ្ញាអាចមានរយះពេលខ្លី ប្រហែលពីរបីថ្ងៃ ទោះបើមនុស្សមានសុខភាពល្អក្តី ក៏អាចឈឺអស់រយៈពេលជាច្រើនអាទិត្យ ។

- **មនុស្សភាគច្រើនពុំមានរោគសញ្ញាអ្វីទេ ។** មនុស្សប្រហែលជា 80 ភាគរយ (ប្រហែល 4 ក្នុងចំណោម 5 នាក់ ) ដែលបានឆ្លងមេរោគ WNV មិនបង្ហាញឲ្យឃើញរោគសញ្ញាអ្វីសោះឡើយ ។



DEPARTMENT OF HEALTH AND HUMAN SERVICES
CENTERS FOR DISEASE CONTROL AND PREVENTION
SAFER • HEALTHIER • PEOPLE™

## តើមេរោគ WNV ឆ្លងដោយវិធីណា?

- **តាមមូសដែលមានមេរោគ ។** ជារឿយៗ មេរោគ WNV បានឆ្លងដោយសារមូសដែលមានរោគបានខាំ ។ មូសជាអ្នកពាំនាំមេរោគ WNV ដោយក្លាយជាបានឆ្លងមេរោគនៅពេលវាស៊ីសត្វស្លាបដែលមានមេរោគ ។ បន្ទាប់មក មូសដែលបានឆ្លងមេរោគ អាចចំឡង WNV ទៅមនុស្ស និងសត្វផ្សេងៗទៀតនៅពេលដែលវាខាំ ។
- **តាមការបញ្ចូលឈាម ការផ្សាំ, និងពីម្តាយទៅកូន ។** ក្នុងករណីតិចតួចបំផុត ដែលមេរោគ WNV អាចឆ្លងតាមរយៈការបញ្ចូលឈាម ការផ្សាំសរីរាង្គ និងការបំបៅកូន និងការឆ្លងពីម្តាយទៅកូននៅក្នុងកំឡុងពេលមានផ្ទៃពោះ ។
- **មិនឆ្លងតាមរយៈការប៉ះពាល់ទេ ។** មេរោគ WNV មិនឆ្លងតាមការទាក់ទងធម្មតាដូចជាការប៉ះ ឬការថើបមនុស្សដែលមានមេរោគទេ ។

## តើយូរប៉ុន្មានទៅ ទើបមនុស្សដែលមានមេរោគនេះចាប់ផ្តើមឈឺ?

ជាទូទៅ មនុស្សនឹងមានរោគសញ្ញាក្នុងរយៈពេលរវាង 3 ឬ 14 ថ្ងៃ បន្ទាប់ពីមូសដែលមានមេរោគបានខាំ ។

## តើព្យាបាលនៃការឆ្លងមេរោគ WNV ដោយវិធីណា?

ពុំមានការព្យាបាលមេរោគនេះដោយជាក់លាក់ណាមួយទេ ។ ក្នុងករណីដែលមានរោគសញ្ញាស្រាលៗ នោះគេនឹងមានរោគសញ្ញាដូចជា គ្រុនក្តៅ និងឈឺខ្លួនប្រាណ ដែលឈឺរាលដាលដោយខ្លួនឯង ។ ចំណែកក្នុងករណីធ្ងន់ធ្ងរវិញ គេតែងតែត្រូវទៅមន្ទីរពេទ្យ ដើម្បីទទួលការព្យាបាល រួមទាំងការចាក់តាមសរសៃ ទទួលជំនួយក្នុងការដកដង្ហើម និងការថែរក្សាសុខភាព ។

## តើខ្ញុំគួរតែធ្វើដូចម្តេច បើខ្ញុំគិតថាខ្ញុំមានមេរោគ WNV?

ជំងឺ WNV ស្រាលៗ អាចនឹងបានធូរស្រាលវិញដោយខ្លួនឯង ហើយមិនចាំបាច់ស្វែងរកការព្យាបាលទេ តែទោះជាយ៉ាងណាក្តី ក៏គេអាចទៅព្យាបាលបានដែរ ។ ប្រសិនបើអ្នកមានរោគសញ្ញាជំងឺ WNV ធ្ងន់ធ្ងរ ដូចជាឈឺក្បាលខ្លាំង ឬក៏វង្វេងខុសប្លែកពីធម្មតា អ្នកត្រូវស្វែងរកការព្យាបាលជាបន្ទាន់ ។ ជំងឺធ្ងន់ធ្ងរនេះជាទូទៅដំរូវឲ្យស្នាក់នៅមន្ទីរពេទ្យ ។ ស្ត្រីដែលមានផ្ទៃពោះ និងម្តាយដែលបំបៅដោះកូន ដំរូវឲ្យពិគ្រោះជាមួយវេជ្ជបណ្ឌិត ក្រែងលោគេមានរោគសញ្ញា WNV ។

## តើជំងឺដែលបណ្តាលមកពី WNV មានគ្រោះថ្នាក់អ្វីខ្លះ?

**មនុស្សដែលមានអាយុលើស 50 ឆ្នាំ មានគ្រោះថ្នាក់ខ្លាំងជាង ។** មនុស្សដែលមានអាយុលើសពី 50 ឆ្នាំ ទំនងជានឹងកើតមានរោគសញ្ញា WNV ធ្ងន់ធ្ងរ ហើយប្រសិនបើគាត់មានជំងឺ នោះគាត់គួរតែថែទាំខ្លួនយ៉ាងពិសេស ដោយប្រុងប្រយ័ត្នជៀសវាងកុំឲ្យមូសខាំ ។

**ការនៅខាងក្រៅ មានន័យថាអ្នកឋិតក្នុងភាពគ្រោះថ្នាក់ ។** កាលណាអ្នកចេញទៅខាងក្រៅញឹកញាប់ នោះមូសដែលមានមេរោគ WNV នឹងខាំអ្នករឹតតែខ្លាំងឡើង ។ បើចំណាយពេលច្រើននៅក្រៅផ្ទះ ទោះជានៅពេលធ្វើការ ឬនៅពេលលេងខាងក្រៅផ្ទះ ត្រូវប្រយ័ត្នជៀសវាងកុំឲ្យមូសខាំ ។

**ការគ្រោះថ្នាក់តាមវិធីពេទ្យមានកំរិតទាបណាស់ ។** ការឲ្យឈាម ត្រូវបានគេពិនិត្យមើល WNV ជាស្រេច មុននឹងគេយកមកប្រើ ។ ការគ្រោះថ្នាក់ដោយឆ្លង WNV តាមរយៈការបញ្ចូលឈាម និងការផ្សាំសរីរាង្គមានកំរិតទាបណាស់ ហើយមនុស្សដែលត្រូវការវះកាត់មិនគួរភ័យខ្លាចឡើយ ។ ប្រសិនបើអ្នកមានចំងល់អ្វី សូមពិគ្រោះជាមួយគ្រូពេទ្យរបស់អ្នក ។ **ការមានផ្ទៃពោះនិងការបំបៅកូន មិនបណ្តាលឲ្យមានគ្រោះថ្នាក់*ដោយសារការឆ្លងមេរោគ* WNV ទេ ។** គេកំពុងតែវាយដំឡៃពីការគ្រោះថ្នាក់ដែល WNV អាចកើតមាននៅក្នុងទារកក្នុងផ្ទៃ ឬទារកទើបកើត ដែលបានឆ្លងតាមរយៈទឹកដោះ ។ សូមពិគ្រោះយោបល់ជាមួយគ្រូពេទ្យរបស់អ្នក ។



DEPARTMENT OF HEALTH AND HUMAN SERVICES
CENTERS FOR DISEASE CONTROL AND PREVENTION
SAFER • HEALTHIER • PEOPLE™

## តើ CDC កំពុងតែចាត់វិធានការអ្វីខ្លះចំពោះ WNV?

មជ្ឈមណ្ឌលសំរាប់ទប់ទល់ និងបង្ការជំងឺ (Centers for Disease Control and Prevention CDC) កំពុងតែធ្វើការជាមួយក្រសួងសុខាភិបាលរដ្ឋ និងក្រសួងសុខាភិបាលតាមតំបន់ ជាមួយនាយកដ្ឋានភោជនភណ្ឌ និងឱសថ្ហបករណ៍ (FDA) ព្រមទាំងកំពុងធ្វើការជាមួយភ្នាក់ងាររដ្ឋាភិបាលឯទៀត និងឧស្សាហកម្មឯកជន ដើម្បីរៀបចំ និងការពារបញ្ហាជំងឺ WNV ថ្មី ។

*កិច្ចការខ្លះដែល CDC កំពុងធ្វើ មានដូចជា :*

- សម្របសម្រួលទិន្នន័យអេឡិចត្រូនិក ទូទាំងប្រជាជាតិ ដែលរដ្ឋចែករំលែកពត៌មានអំពី WNV
- ជួយរដ្ឋឲ្យបង្កើត និងអនុវត្តកម្មវិធីការពារមូស និងទប់ទល់
- បង្កើតឲ្យមានវិធីពិនិត្យពិសោធឲ្យបានគ្រាន់បើ រហ័សជាង ដើម្បីរក និងវិភាគមេរោគ WNV
- បង្កើតសំភារៈអប់រំ និងកម្មវិធីផ្សព្វផ្សាយដំណឹង សំរាប់សាធារណជន និងអ្នកវិជ្ជាជីវៈខាងសុខភាព
- បើកមន្ទីរពិសោធន៍ថ្មី សំរាប់ពិសោធមើល WNV

## តើខ្ញុំគួរតែដឹងអំពីអ្វីទៀត?

**ប្រសិនបើអ្នកឃើញសត្វស្លាបងាប់ :** ចូរកុំកាន់វាដោយដៃទទេឲ្យសោះ ។ ត្រូវទាក់ទងទៅក្រសួងសុខាភិបាលក្នុងតំបន់របស់អ្នក ដើម្បីសុំការណែនាំស្តីអំពីវិធីរាយការណ៍ និងរបៀបបោះសត្វស្លាបដែលងាប់នោះចោល ។

ដើម្បីឲ្យបានពត៌មានបន្ថែម សូមបើកមើលអន្តរបណ្តាញ www.cdc.gov/westnile ឬទូរស័ព្ទមកខ្សែប្រចាំការឆ្លើយតបសាធារណៈនៅ CDC តាមទូរស័ព្ទលេខ (888) 246-2675 (ភាសាអង់គ្លេស) (888) 246-2857 (ភាសាអេស្ប៉ាញុល) ឬ (866) 874-2646 (TTY) ។



**DEPARTMENT OF HEALTH AND HUMAN SERVICES**
**CENTERS FOR DISEASE CONTROL AND PREVENTION**
**SAFER • HEALTHIER • PEOPLE™**